# អគ្គលេខាធិការ អ.ស.ប សម្តែងកង្វល់អំពីប្រទេសកម្ពុជា

សំណួរ៖ ពិតហើយ ខ្ញុំចង់សួរអំពីប្រទេសកម្ពុជា និងប្រទេសកូរ៉េខាងត្បូង។ អំពីប្រទេសកម្ពុជា តើការិយាល័យលោកមានបានចេញសេចក្តីថ្លែងការណ៍ណាមួយពីកង្វល់អំពីការបង្ក្រាបនៅទីនោះទេ? ពីព្រោះខ្លះ....និយាយថាសេចក្តីថ្លែងការណ៍បានចេញហើយ ហើយវាមិនបាននិយាយអ្វីច្រើនដែលគួរភ្ញាក់ផ្អើលខ្លាំងឡើយ។ គេនិយាយថាសេចក្តីថ្លែងការណ៍នោះមិនបាននិយាយចំៗទេ....គ្រាន់តែនិយាយធម្មតាៗថា ហ៊ុន សែន បង្ក្រាបគណបក្សប្រឆាំង។ វាមិនមែនជារឿងទូរភាគីទេ។ អញ្ចឹងហើយ ខ្ញុំកំពុងសម្លឹងមើលការតទល់គ្នានៅទីនោះ។ តើមានសេចក្តីថ្លែងការណ៍ណាមួយអំពីកម្ពុជាទេ?

អ្នកនាំពាក្យ៖ ជានិច្ចជាកាល ខ្ញុំពេញចិត្តនឹងការវិភាគលើការឆ្លើយតបរបស់យើង។ គេបានសួរយើងហើយ យើងក៏បានឆ្លើយហើយដែរ។ មិនមានសេចក្តីថ្លែងការណ៍ណាមួយបានចេញនោះទេ ហើយដោយសារថាខ្ញុំ... ខ្ញុំយល់ថាអ្នកកំពុងសួរខ្ញុំអំពីជំហររបស់យើង។ ពិតណាស់ លោកអគ្គលេខាធិការមានកង្វល់អំពីភាពតានតឹងកំពុងកើនឡើងរវាងគណបក្សកាន់អំណាច និងគណបក្សប្រឆាំងនៅកម្ពុជា ជាពិសេស ការចាប់ខ្លួន ឬការប៉ុនប៉ងចាប់ខ្លួនសមាជិកសភា ដែលមានអភ័យឯកសិទ្ធិសភា។ បរិយាកាសមួយនៃកិច្ចសន្ទនាបែបប្រជាធិបតេយ្យដែលគ្មានការគំរាមកំហែងគឺសំខាន់សម្រាប់ស្ថិរភាពនយោបាយ និងសង្គមមួយដែលមានសន្តិភាពនិងវិបុលភាព។

សំណួរ៖ មែនហើយ។ ប៉ុន្តែអ្នកបានឃើញមតិរិះគន់ ដែលនេះទំនងជាទាក់ទងនឹងគណបក្សប្រឆាំងដែលត្រូវបានចាប់ខ្លួន ព្រោះតែ..........

អ្នកនាំពាក្យ៖ ខ្ញុំគិតថាអ្នកណាក៏មានសេរីភាពក្នុងការវិភាគ និងសិក្សាស្វែងយល់ពីសេចក្តីថ្លែងការណ៍របស់យើង។ យើងយល់ថាវាអាចជាករណីនោះ។